BRIEFING NOTES

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**អ្នកនាំពាក្យរបស់ឧត្តមស្នងការ អ ប.ស.ទទួលបន្ទុកសិទ្ធិមនុស្ស៖** អ្នកស្រី រ៉ាវីណា សេមសាដានី (Ravina Shamdasani)

**ទីតាំង៖** ទីក្រុងហ្សឺណែវ

**កាលបរិច្ឆេទ៖** ថ្ងៃសុក្រទី១៧ ខែសីហា ឆ្នាំ២០១៨

## កំណត់សង្ខេបស្តីពីប្រទេសកម្ពុជា

យើងមានកង្វល់អំពីបរិយាកាសសិទ្ធិមនុស្សជុំវិញការបោះឆ្នោតដែលបានប្រព្រឹត្តទៅកាលពីពេលថ្មីៗនេះ នៅប្រទេសកម្ពុជា ដោយមិនមានការចូលរួមពីគណបក្សប្រឆាំងមួយដ៏សំខាន់ដែលត្រូវបានរំលាយ គឺគណបក្សសង្គ្រោះជាតិ (CNRP)។ បញ្ហានេះ បានបន្សល់ទុកប្រជាពលរដ្ឋក្នុងចំនួនសមាមាត្រដ៏ធំដែលមិនបានជ្រើសរើសតំណាងរបស់ខ្លួន ហើយដែលបណ្តាលឲ្យមានកង្វល់ចំពោះសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងជីវភាពនយោបាយ។ មានសេចក្តីរាយការណ៍ថាប្រជាពលរដ្ឋត្រូវគេគំរាមកំហែង ឬទិញសំលេងបោះឆ្នោត ហើយអង្គការសង្គមស៊ីវិលមួយចំនួនបានប្រឈមនឹងការយាយីរំខាននៅក្នុងការបោះឆ្នោត។ គេហទំព័រដ៏ពេញនិយមចំនួនដប់ប្រាំពីរ ត្រូវបានបិទនៅអំឡុងថ្ងៃបោះឆ្នោត។ មានការរឹតបន្តឹងបន្ថែមទៀត ទៅលើសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកបោះឆ្នោត និងគូប្រជែងនយោបាយដែលបានអំពាវនាវឲ្យមានការធ្វើពហិការ ឬប្រកាសពីចេតនារបស់ខ្លួន ក្នុងការមិនចេញទៅបោះឆ្នោតនៅក្នុងការបោះឆ្នោត រួមទាំងតាមរយៈការគំរាមកំហែង ការពិន័យជាប្រាក់ និងការចាត់វិធានការតាមផ្លូវច្បាប់ជាដើម។ យើងជម្រុញឲ្យរដ្ឋាភិបាលបញ្ឈប់ការចាត់វិធានការផ្លូវច្បាប់ក្នុងករណីបែបនេះ។ តាមច្បាប់សិទ្ធិមនុស្ស សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការពារការអំពាវនាវឲ្យធ្វើពហិការក្នុងការបោះឆ្នោតមួយដែលមិនមានលក្ខណៈជាកំហិត។

ដោយសារថា ឥឡូវនេះលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជាតិ ត្រូវបានប្រកាសកាលពីថ្ងៃពុធ យើងសូមអំពាវនាវដល់រដ្ឋាភិបាលឲ្យបង្កើតបរិយាកាសមួយសម្រាប់ការជជែកពិភាក្សានយោបាយមួយបើកចំហ និងមានលក្ខណៈបរិយាបន្ន ដែលអនុញ្ញាតឲ្យសម្លេងទាំងអស់នៅកម្ពុជា ត្រូវបានគេស្តាប់ដឹងឮ។

យើងជម្រុញឲ្យរដ្ឋាភិបាលដោះលែងអ្នកនយោបាយគណបក្សប្រឆាំង អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្សនិងប្រជាពលរដ្ឋសាមញ្ញដែលត្រូវបានគេឃុំខ្លួនដោយសារតែការអនុវត្តសិទ្ធិមនុស្ស ជាពិសេស សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ យើងសូមអំពាវនាវផងដែរ ដល់រដ្ឋាភិបាលឲ្យលុបចោលបម្រាមទៅលើគូប្រជែង មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយ ការពារនិងពង្រីកលំហសម្រាប់សកម្មភាពសង្គមស៊ីវិល។

ការគោរពសិទ្ធិមនុស្ស និង សង្គមស៊ីវិលមួយដែលរស់រវើក ដែលមានលំហសម្រាប់ការជជែកដេញដោល ស្ទើរតែអំពីបញ្ហាស្មុគស្មាញ និងមានលក្ខណៈវាទប្បដិវាទ គឺជាគ្រឿងផ្សំដ៏សំខាន់ ប្រសិនជាជម្លោះនៅក្នុងអតីតកាលនឹងត្រូវបានបញ្ចៀស ហើយប្រសិនជាការអភិវឌ្ឍនឹងត្រូវធ្វើប្រកបដោយសន្តិភាព និងនិរន្តរភាព។

**ចប់**

*សម្រាប់**ការសាកសួរព័ត៌មាន** សូមទាក់ទង៖ អ្នកស្រី **រ៉ាវីណា សេមសាដានី** Ravina Shamdasani តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩១៦៩ ឬ អ៊ីម៉ែល rshamdasani@ohchr.org) ឬ អ្នកស្រី **លីស ស្រូសែល** Liz Throssell តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៤៦៦ ឬ អ៊ីម៉ែល ethrossell@ohchr.org) ។*

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោកផ្នែកអត្ថបទដែលត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា "មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ"។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖***
*www.standup4humanrights.org*.